00223326

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

A190/II/6

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១២)

ចំពោះមុខ: ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ១០ កញ្ញា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 09 / 2008
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

សាធារណៈ:

សេចក្តីសម្រេចលើសំណើសុំអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / 09 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ជនត្រូវចោទ**

អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គីមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky
យុង ផានិត

**សហមេធាវីការពារក្តី**

អាង ឧត្តម
Michael G. KARNAVAS

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”)** បានទទួលលិខិតរបស់ Sadie Blanchard និង Annie Gell ជាមន្ត្រីជំនួយផ្នែកច្បាប់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-CAM) (ដែលមានភ្ជាប់មកជាមួយ) ចុះថ្ងៃទី ២៥ កក្កដា ២០០៨ ដែលបានស្នើសុំការអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីស្តីពី “ការបកប្រែឯកសារ”។ លិខិតនេះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ប្រឆាំងនឹងដីកាបង្គាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ស្តីពីសិទ្ធិ និងកាតព្វកិច្ចបកប្រែរបស់ភាគី (“បណ្តឹងឧទ្ធរណ៍”)។

២. វិធាន ៣៣(១) នៃវិធានផ្ទៃក្នុង ចែងថា:

> នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសអោយបានត្រឹមត្រូវ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចអញ្ជើញ ឬផ្តល់ឱកាសអោយអង្គការ ឬបុគ្គលណាមួយប្រគល់ជូននូវសារណាជាលាយល័ក្ខអក្សរ ពាក់ព័ន្ធទៅនឹងបញ្ហាណាមួយក៏បានក្នុងនាមជាអ្នកឯកទេសអមតុលាការ។ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ដែលពាក់ព័ន្ធត្រូវកំណត់ពេលវេលាអោយដាក់សារណានេះ ប្រសិនបើត្រូវធ្វើ។

៣. អង្គបុរេជំនុំជម្រះយល់ឃើញថា តាមរយៈសារណារបស់ភាគី អង្គជំនុំជម្រះមានព័ត៌មានគ្រប់គ្រាន់ក្នុងការសម្រេចបណ្តឹងឧទ្ធរណ៍នេះ។ នៅក្នុងកាលៈទេសៈទាំងនេះ យើងមិនចង់ឱ្យមានហានិភ័យណាមួយចំពោះការពន្យារពេលនីតិវិធី ដោយសារការទទួលយកសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី និងសេចក្តីសន្និដ្ឋានតបរបស់ភាគី។

៤. អង្គបុរេជំនុំជម្រះស្វាគមន៍ការចាប់អារម្មណ៍ដែលបានលើកឡើងដោយ Sadie Blanchard និង Annie Gell នៅក្នុងកិច្ចដំណើរការនីតិវិធីមួយនេះ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ខ្លួនមិនមានបំណងផ្តល់ការអនុញ្ញាតចំពោះសំណើសុំដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីនៅក្នុងករណីនេះឡើយ។

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច:**

បដិសេធ សំណើសុំការអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។៚

ភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ប្រាក់ គឹមសាន